ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈឆ្មបកម្ពុជា**

# គោលការណ៍ណែនាំ

# ស្ដីពី

# ស្តង់ដានៃការផ្តល់អាជ្ញាប័ណ្ណឡើងវិញ និងលក្ខខណ្ឌតម្រូវ ក្នុងការអភិវឌ្ឍន៍វិជ្ជាជីវៈបន្តសម្រាប់ឆ្មបក្នុង ព្រះរាជាណាចក្រកម្ពុជា

ខែមិថុនា ឆ្នាំ២០១៧

# អារម្ភកថា

ខ្ញុំមានសេចក្តីសោមនស្សរីករាយក្រៃលែង ក្នុងការដាក់ឲ្យប្រើប្រាស់នូវគោលការណ៍ណែនាំស្តីពីស្តង់ដានៃការផ្តល់អាជ្ញាប័ណ្ណឡើងវិញ និងលក្ខខណ្ឌតម្រូវក្នុងការអភិវឌ្ឍន៍វិជ្ជាជីវៈបន្តសម្រាប់ឆ្មបក្នុងព្រះរាជាណាចក្រកម្ពុជា ជាលើកដំបូងនេះ ។

តាមរយៈការចុះបញ្ជិកានិងផ្តល់អាជ្ញាប័ណ្ណរបស់ឆ្មបទាំងអស់ គណៈឆ្មបកម្ពុជាបានខិតខំរៀបចំឲ្យមានបទបញ្ញត្តិជាច្រើន ដែលទាក់ទងនឹងការអនុវត្តការងាររបស់ឆ្មប ដើម្បីធានាឲ្យបាននូវស្តង់ដាវិជ្ជាជីវៈខ្ពស់ប្រកបដោយគុណភាពក្នុងការផ្តល់សេវាថែទាំជូនសាធារណៈជន និងចូលរួមកាត់បន្ថយអត្រាមរណៈភាពមាតា និងទារក ។

គោលការណ៍ណែនាំនេះ តម្រូវឲ្យសមាជិកគណៈឆ្មបកម្ពុជាទាំងអស់ដែលកំពុងអនុវត្តការងារក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវសុំបន្តអាជ្ញាប័ណ្ណឡើងវិញជាមួយគណៈឆ្មបកម្ពុជារៀងរាល់០៣ឆ្នាំម្តង សម្រាប់ឆ្មបជនជាតិខ្មែរ និងរៀងរាល់០១ឆ្នាំម្តង សម្រាប់ឆ្មបជនជាតិបរទេស ។ ដើម្បីផ្តល់អាជ្ញាប័ណ្ណឡើងវិញបាន ឆ្មបជនជាតិខ្មែរ និងឆ្មបជនជាតិបរទេស ចាំបាច់ត្រូវអនុវត្តន៍តាមគោលការណ៍ណែនាំនេះឲ្យបានខ្ជាប់ខ្ជួន និងធ្វើឲ្យប្រសើរឡើងវិញក្នុងការធ្វើបច្ចុប្បន្នភាព និងអភិវឌ្ឍន៍ចំណេះដឹង និងជំនាញរបស់ខ្លួន ។

គណៈឆ្មបកម្ពុជាសង្ឃឹម និងជឿជាក់ថា តាមរយៈគោលការណ៍ណែនាំនេះ ឆ្មបទាំងអស់នឹងខិតខំកែប្រែឥរិយាបទក្នុងការអនុវត្តន៍ការងាររបស់ខ្លួន ដើម្បីផ្តល់ការថែទាំប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់បំផុតសម្រាប់ស្ត្រី និងទារក ។

**រាជធានីភ្នំពេញ. ថ្ងៃទី** ២០ **ខែ** មិថុនា **ឆ្នាំ២០១៧**

**ជ. ក្រុមប្រឹក្សាគណៈឆ្មបជាតិ**

**ប្រធាន**

គណៈឆ្មបកម្ពុជា
CAMBODIAN MIDWIVES COUNCIL

**ហែម_ណារី**

## I-សេចក្តីផ្តើម

គណៈឆ្មបកម្ពុជាគឺជាអង្គភាពមួយដែលតាមដានការអនុវត្តវិជ្ជាជីវៈរបស់ឆ្មបក្នុងប្រទេសកម្ពុជា និងទទួលខុសត្រូវលើការលើកកម្ពស់ស្តង់ដានៃការថែទាំរបស់ឆ្មប ក្នុងគោលបំណងដើម្បីបម្រើ និងការពារសាធារណជន។

គោលការណ៍ណែនាំនេះនឹងជួយដល់ឆ្មបទាំងអស់ដែលកំពុងអនុវត្តន៍ការងារឆ្មបក្នុងប្រទេសកម្ពុជា ឲ្យធ្វើបច្ចុប្បន្នភាព និងអភិវឌ្ឍចំណេះដឹងនិងជំនាញរបស់ខ្លួន ដើម្បីផ្តល់ការថែទាំដ៏ល្អបំផុតសម្រាប់ស្ត្រីនិងគ្រួសារ។ ឆ្មបអនុវត្តវិជ្ជាជីវៈឆ្មប គ្រូបង្រៀនឆ្មប អ្នកគ្រប់គ្រងឆ្មប អ្នកស្រាវជ្រាវការងារឆ្មប ដែលការងារនោះមានឥទ្ធិពលលើការអនុវត្តការងាររបស់ឆ្មប ឆ្មបដែលបានចុះបញ្ជិកានិងទទួលបានអាជ្ញាប័ណ្ណទាំងអស់មានកាតព្វកិច្ចក្នុងការបំពេញតាមស្តង់ដានៃការផ្តល់អាជ្ញាប័ណ្ណឡើងវិញនិងលក្ខខណ្ឌតម្រូវក្នុងការអភិវឌ្ឍន៍វិជ្ជាជីវៈបន្ត។

ការអភិវឌ្ឍវិជ្ជាជីវៈបន្តគឺអាចបត់បែនបាន ហើយវាអាស្រ័យលើឆ្មបក្នុងការសម្រេចចិត្តជ្រើសរើសវគ្គបណ្តុះបណ្តាលដែលខ្លួនត្រូវការ ដើម្បីបំពេញតាមលក្ខខណ្ឌតម្រូវនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ប៉ុន្តែការជ្រើសរើសនោះត្រូវអនុលោមទៅតាមពិធីសារជាតិស្តីពី ក្របខណ្ឌសមត្ថភាពស្នូលសម្រាប់វិជ្ជាជីវៈឆ្មប និងឯកសារណែនាំផ្សេងៗទៀតរបស់ក្រសួងសុខាភិបាល។

គោលការណ៍ណែនាំនេះរួមមាន៖ ការធ្វើផែនការ ការបំពេញការអភិវឌ្ឍន៍វិជ្ជាជីវៈបន្ត និងភស្តុតាងពីលទ្ធផលនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត។

## II- តួនាទីរបស់គណៈឆ្មបកម្ពុជា

គណៈឆ្មបកម្ពុជាមានតួនាទីដូចតទៅ៖

- ចុះបញ្ជិកានិងផ្តល់អាជ្ញាប័ណ្ណដល់ឆ្មបដែលមានគុណវុឌ្ឍិគ្រប់គ្រាន់ ។
- រៀបចំស្តង់ដាសមត្ថភាពឆ្មប និងក្រមសីលធម៌ឆ្មប ។
- រៀបចំស្តង់ដាសម្រាប់ការបណ្តុះបណ្តាលឆ្មបមុន/ក្រោយមូលដ្ឋាន និងធ្វើការបណ្តុះបណ្តាល
- រៀបចំគោលការណ៍ណែនាំស្តីពី ស្តង់ដានៃការផ្តល់អាជ្ញាប័ណ្ណឡើងវិញ និងលក្ខខណ្ឌតម្រូវក្នុងការអភិវឌ្ឍវិជ្ជាជីវៈបន្ត ។
- ស៊ើបអង្កេតនិងដោះស្រាយលើបណ្តឹងឆ្មប ។
- ផ្តល់ព័ត៌មានស្តីពី ស្តង់ដានៃការអនុវត្តវិជ្ជាជីវៈឆ្មប។ល។

## III- ហេតុអ្វីបានជាការអភិវឌ្ឍវិជ្ជាជីវៈបន្តមានសារៈសំខាន់ចំពោះឆ្មប?

ការអភិវឌ្ឍវិជ្ជាជីវៈបន្តនឹងជួយឆ្មបក្នុងការបង្ហាញដល់ស្ត្រី គ្រួសាររបស់គាត់ និងសហាភាតរៈរបស់ឆ្មបថាខ្លួនកំពុងធ្វើបច្ចុប្បន្នភាពក្នុងការអភិវឌ្ឍវិជ្ជាជីវៈបន្ត និងបង្ហាញពីចំណេះដឹង និងជំនាញដែលខ្លួនត្រូវធ្វើការអភិវឌ្ឍ។ ការបំពេញការអភិវឌ្ឍវិជ្ជាជីវៈបន្តប្រកបដោយប្រសិទ្ធិភាពនឹងជួយឆ្មប

អាចប៉ាន់ស្មានពីតម្រូវការ និងឆ្លើយតបទៅនឹងតម្រូវការថែទាំសុខភាពដែលមានការផ្លាស់ប្តូរ និងពង្រឹងស្តង់ដានៃការថែទាំរបស់ខ្លួន។

ភស្តុតាងនៃការស្រាវជ្រាវផ្នែកថែទាំបង្ហាញថា ក្នុងរយៈពេល៥ឆ្នាំក្រោយពីបញ្ចប់វគ្គបណ្តុះបណ្តាលមូលដ្ឋាន ចំណេះដឹងដែលទទួលបានក្លាយជាហួសសម័យ ហើយបើគ្មានការអភិវឌ្ឍវិជ្ជាជីវៈបន្តទេនោះ ការថែទាំនឹងប្រព្រឹត្តទៅដោយពុំមានគុណភាពនិងអាចនាំឲ្យមានគ្រោះថ្នាក់ (ស្លាប់ ឬពិការភាព) ដល់ស្ត្រីនិងទារក។ ដូច្នេះអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលទាំងអស់ចាំបាច់ត្រូវអភិវឌ្ឍចំណេះដឹងនិងជំនាញរបស់ខ្លួនជាប្រចាំ។ ការអភិវឌ្ឍវិជ្ជាជីវៈបន្តមិនធានាថាឆ្មបមានសមត្ថភាពគ្រប់គ្រាន់១០០% នោះទេ ប៉ុន្តែវាជាសូចនាករដ៏សំខាន់មួយក្នុងការធានានូវគុណភាពនៃការថែទាំ។

## IV-តើគោលការណ៍ណែនាំនេះប្រើសម្រាប់អ្នកណា?

គោលការណ៍ណែនាំនេះ ប្រើសម្រាប់ឆ្មបដែលបានចុះបញ្ជិកា និងកំពុងអនុវត្តវិជ្ជាជីវៈឆ្មបក្នុងប្រទេសកម្ពុជា ហើយក៏អាចមានសារៈប្រយោជន៍ផងដែរសម្រាប់ប្រធានអង្គភាពដែលឆ្មបកំពុងបំពេញការងារ ស្ត្រី និងសាធារណជន ដើម្បីឲ្យពួកគេយល់ពីតួនាទីរបស់គណៈឆ្មបកម្ពុជាក្នុងការកំណត់ស្តង់ដានៃការអនុវត្តវិជ្ជាជីវៈឆ្មប។

## V- លក្ខខណ្ឌតម្រូវនិងស្តង់ដានៃការផ្តល់អាជ្ញាប័ណ្ណឡើងវិញ

### ១- លក្ខខណ្ឌតម្រូវនិងស្តង់ដា នៃការអនុវត្តវិជ្ជាជីវៈឆ្មប ៖

គោលបំណងនៃស្តង់ដានេះគឺដើម្បីការពារសាធារណជនដោយធានាថា ឆ្មបដែលបានផ្តល់អាជ្ញាប័ណ្ណឡើងវិញបានបំពេញតាមលក្ខខណ្ឌតម្រូវនៃការអនុវត្តវិជ្ជាជីវៈឆ្មប ដើម្បីធានាថាសេវាដែលខ្លួនបានផ្តល់មានសុវត្ថិភាព។

**ក- ឆ្មបជនជាតិខ្មែរ ៖**

- ឆ្មបជនជាតិខ្មែរទាំងអស់ដែលបានចុះបញ្ជិកា និងកំពុងអនុវត្តការងារឆ្មបក្នុងព្រះរាជាណាចក្រកម្ពុជា ដែលទទួលបានអាជ្ញាប័ណ្ណប្រកបវិជ្ជាជីវៈ ត្រូវបន្តអាជ្ញាប័ណ្ណឡើងវិញជាមួយគណៈឆ្មបកម្ពុជារៀងរាល់៣ឆ្នាំម្តង។
- ឆ្មបជនជាតិខ្មែរដែលអនុវត្តវិជ្ជាជីវៈឆ្មប ត្រូវប្រើប្រាស់នូវគុណវុឌ្ឍិរបស់ខ្លួនយ៉ាងតិចបំផុត ៥០០ម៉ោង ក្នុង១ឆ្នាំ ឬ ១,៥០០ម៉ោង ក្នុងរយៈពេល៣ឆ្នាំ មុននឹងកាលបរិច្ឆេទកំណត់នៃការផ្តល់អាជ្ញាប័ណ្ណឡើងវិញ។

**ខ- ឆ្មបបរទេស៖**

- ឆ្មបបរទេសទាំងអស់ដែលបានចុះបញ្ជិកា និងកំពុងអនុវត្តការងារឆ្មបក្នុងព្រះរាជាណាចក្រ

កម្ពុជា ដែលទទួលបានអាជ្ញាប័ណ្ណប្រកបវិជ្ជាជីវៈ ត្រូវបន្តអាជ្ញាប័ណ្ណឡើងវិញជាមួយគណៈឆ្មបកម្ពុជារៀងរាល់១ឆ្នាំម្តង។

– ឆ្មបបរទេសដែលអនុវត្តវិជ្ជាជីវៈឆ្មបត្រូវប្រើប្រាស់នូវគុណវុឌ្ឍិរបស់ខ្លួនយ៉ាងតិចបំផុត៥០០ម៉ោង ក្នុងរយៈពេល១ឆ្នាំ មុននឹងកាលបរិច្ឆេទកំណត់នៃការផ្តល់អាជ្ញាប័ណ្ណឡើងវិញ និងបំពេញតាមលក្ខខណ្ឌតម្រូវផ្សេងទៀតដែលកំណត់ក្នុងសេចក្តីសម្រេចស្តីពី ការកំណត់ប្រភេទ និងលក្ខខណ្ឌនៃការចុះបញ្ជីឆ្មប។

*ប្រសិនបើឆ្មបមិនបានបំពេញតាមលក្ខខណ្ឌខាងលើទេនោះ ឆ្មបជនជាតិខ្មែរនិងបរទេសត្រូវ៖

– អនុវត្តការងារស្ថិតក្រោមការអភិបាលដោយឆ្មបដែលបានចុះបញ្ជិកាក្នុងប្រភេទឆ្មបទូទៅ ក្នុងរយៈពេល៣ខែនិងទទួលបានលិខិតបញ្ជាក់សមត្ថភាព ដើម្បីធានាថាឆ្មបមានចំណេះដឹង និងជំនាញថ្មីៗ អាចឆ្លើយតបទៅនឹងសមត្ថភាពស្នូល និងក្រមសីលធម៌ឆ្មបដែលកំណត់ដោយគណៈឆ្មបកម្ពុជា។

**ចំណាំ៖ សម្រាប់គ្រូបណ្តុះបណ្តាលឆ្មប ( សាលាបណ្តុះបណ្តាលឆ្មប សាធារណៈ និង ឯកជន )

ការផ្តល់អាជ្ញាប័ណ្ណឡើងវិញគឺមានសារៈសំខាន់ សម្រាប់ការការពារសុវត្ថិភាពសាធារណជន និងមានន័យថាឆ្មបដែលបានផ្តល់អាជ្ញាប័ណ្ណទាំងអស់ បានបំពេញតាមលក្ខខណ្ឌនៃការចុះបញ្ជីរបស់គណៈឆ្មបកម្ពុជា។

**២-លក្ខខណ្ឌតម្រូវនិងស្តង់ដានៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ៖**

**ក/ ឆ្មបជនជាតិខ្មែរនិងបរទេសត្រូវ៖**

– ទទួលបាននូវការអភិវឌ្ឍវិជ្ជាជីវៈបន្តយ៉ាងតិចបំផុត៤០ម៉ោងក្នុងរយៈពេល១ឆ្នាំ ឬ១២០ម៉ោងក្នុងរយៈពេល៣ឆ្នាំដែលការសិក្សានោះទាក់ទងនឹងការងារដែលឆ្មបកំពុងអនុវត្ត។

– កត់ត្រានូវកំណត់ហេតុនៃការសិក្សារបស់ខ្លួន។

– បំពេញពាក្យសុំបន្តអាជ្ញាប័ណ្ណឡើងវិញនិងប្រកាសថាខ្លួនបានបំពេញតាមស្តង់ដានៃការបន្តអាជ្ញាប័ណ្ណឡើងវិញ និងលក្ខខណ្ឌតម្រូវក្នុងការអភិវឌ្ឍវិជ្ជាជីវៈបន្ត។

– ឆ្លើយតបតាមសំណើរបស់គណៈឆ្មបកម្ពុជាក្នុងការធ្វើសវនកម្មលើការបំពេញតាមស្តង់ដានិងលក្ខខណ្ឌតម្រូវក្នុងការអភិវឌ្ឍវិជ្ជាជីវៈបន្ត។

*ប្រសិនបើឆ្មបមិនបានបំពេញតាមលក្ខខណ្ឌខាងលើទេនោះ ឆ្មបជនជាតិខ្មែរនិងបរទេសត្រូវ ៖

– ឆ្លងកាត់ការប្រឡងដែលរៀបចំដោយក្រុមប្រឹក្សាគណៈឆ្មបជាតិ និងតម្រូវឲ្យបង់ថវិកាសម្រាប់ការប្រឡងដើម្បីទទួលបានពិន្ទុសម្រាប់បន្តអាជ្ញាប័ណ្ណឡើងវិញ ។

### ខ/ទីកន្លែង និងមធ្យោបាយនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ៖

ឆ្មបអាចអភិវឌ្ឍវិជ្ជាជីវៈបន្តរបស់ខ្លួនតាមមធ្យោបាយផ្សេងៗដោយមិនចាំបាច់មានការអនុម័តពីគណៈឆ្មបកម្ពុជា លើកំណត់ត្រាសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្តរបស់ខ្លួនឡើយដូចជា ៖

ចូលរួមវគ្គបណ្តុះបណ្តាល ឬសិក្ខាសាលាផ្លូវការ ក្រៅផ្លូវការ នៅកន្លែងគ្លីនីករបស់ខ្លួន ការរៀនតាម Online កិច្ចប្រជុំគ្លីនិក ការស្រាវជ្រាវ ការចូលរួមធ្វើសវនកម្មគ្លីនិក កិច្ចប្រជុំក្រុមសម្ព័ន្ធឆ្មប (MCAT) និងធ្វើបទបង្ហាញក្នុងសិក្ខាសាលាឬវគ្គបណ្តុះបណ្តាល ។ល។ ការអភិវឌ្ឍវិជ្ជាជីវៈបន្តត្រូវតែពាក់ព័ន្ធទៅនឹងការងារដែលឆ្មបកំពុងអនុវត្ត និងផ្អែកទៅតាមក្របខណ្ឌសមត្ថភាពស្នូលសម្រាប់វិជ្ជាជីវៈឆ្មបក្នុងព្រះរាជាណាចក្រកម្ពុជា ហើយការសិក្សានេះនឹងអាចជួយឆ្មបផ្តល់ការថែទាំប្រកបដោយគុណភាព។

ស្ថាប័នជាច្រើនដែលផ្តល់ការបណ្តុះបណ្តាលផ្នែកសុខភាពមាតានិងទារករួមមាន៖

- ក្រសួងសុខាភិបាល ( នាយកដ្ឋាន និង អង្គភាពពាក់ព័ន្ធ )
- គណៈឆ្មបកម្ពុជា និងសមាគមឆ្មបកម្ពុជា
- មន្ទីរពេទ្យ និងមជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក
- សាលាបណ្តុះបណ្តាលឆ្មប សាធារណៈ និង ឯកជន
- អង្គការក្រៅរដ្ឋាភិបាល ។ល។

*គ្រប់វគ្គបណ្តុះបណ្តាលឬសិក្ខាសាលាទាំងអស់ ត្រូវផ្អែកទៅតាមក្របខណ្ឌសមត្ថភាពស្នូលសម្រាប់វិជ្ជាជីវៈឆ្មប និងទទួលបានការអនុម័តពីក្រសួងសុខាភិបាល និងជូនដំណឹងមកគណៈឆ្មបកម្ពុជា។

☞<u>សម្រាប់អ្នកបំរើការងារមានប្រាក់បៀវត្ស</u>៖ កន្លែងការងាររបស់ខ្លួនសម្រាប់វិស័យសាធារណៈមានដូចជា៖ សាលាបណ្តុះបណ្តាល មន្ទីរសុខាភិបាល ការិយាល័យស្រុកប្រតិបត្តិ មន្ទីរពេទ្យបង្អែក មណ្ឌលសុខភាព បុស្តិ៍សុខភាព។ល។

សម្រាប់វិស័យឯកជនមានដូចជា៖ គ្លីនិក មន្ទីរពេទ្យ បន្ទប់ថែទាំផ្ទាល់ខ្លួន អង្គការរបស់ខ្លួន ។ល។

☞<u>សម្រាប់អ្នកបម្រើការងារដែលគ្មានប្រាក់បៀវត្ស</u>៖ មានដូចជា៖ ការងារស្ម័គ្រចិត្តសម្រាប់អង្គការសប្បុរសធម៌ ឬក្នុងអំឡុងពេលព្យួរការងារដូចជា៖ ក្នុងអំឡុងពេលរង់ចាំការតែងតាំងតួនាទីនៅក្នុងវិស័យសាធារណៈ ។ល។

### គ/ ឆ្មបមិនអាចផ្តល់អាជ្ញាប័ណ្ណឡើងវិញបានទេ៖

ឆ្មបនឹងមិនអាចត្រូវបានផ្តល់អាជ្ញាប័ណ្ណឡើងវិញបានទេ ប្រសិនបើខ្លួនមិនបានបំពេញតាមស្តង់ដានៃការអភិវឌ្ឍវិជ្ជាជីវៈបន្តនេះ។

ស្តង់ដានៃការផ្តល់អាជ្ញាប័ណ្ណឡើងវិញ និងលក្ខខណ្ឌតម្រូវក្នុងការអភិវឌ្ឍវិជ្ជាជីវៈបន្ត គឺជាស្តង់ដាដែលបង្កើតឡើងដោយគណៈឆ្មបកម្ពុជា សំរាប់ឆ្មបទាំងអស់ត្រូវគោរពតាមដើម្បីខ្លួនអាចបន្តអាជ្ញាប័ណ្ណឡើងវិញបាន។ ឆ្មបអាចទទួលបានការផ្តល់អាជ្ញាប័ណ្ណឡើងវិញលុះត្រាតែក្រុមប្រឹក្សាគណៈឆ្មបរាជធានី -ខេត្ត និងថ្នាក់កណ្តាលដែលខ្លួនបានចុះបញ្ជីកា អនុម័តទទួលនូវពាក្យសុំបន្តអាជ្ញាប័ណ្ណឡើងវិញរបស់ឆ្មប។

ឆ្មបដែលបានចុះបញ្ជិកានិងទទួលបានអាជ្ញាប័ណ្ណទាំងអស់ ត្រូវគោរពតាមស្តង់ដានៃការផ្តល់អាជ្ញាប័ណ្ណឡើងវិញ និងលក្ខខណ្ឌតម្រូវក្នុងការអភិវឌ្ឍវិជ្ជាជីវៈបន្តនេះ។

លើកលែងឆ្មបមិនអនុវត្តជំនាញគ្លីនីក ទោះបីជាឆ្មបប្រភេទនេះត្រូវបានលើកលែងក៏ដោយប៉ុន្តែគណៈឆ្មបកម្ពុជាលើកទឹកចិត្តឲ្យទទួលការបណ្តុះបណ្តាលបន្តដែលទាក់ទងនឹងការងាររបស់ខ្លួន។

## VI- កំណត់ត្រាផ្ទាល់ខ្លួន និងការណែនាំក្នុងការកត់ត្រាសកម្មភាពសិក្សាសំរាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្ត

ក/ កំណត់ត្រាផ្ទាល់ខ្លួនគឺជាកំណត់ត្រាសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្តរបស់ឆ្មប។ ឆ្មបត្រូវទទួលខុសត្រូវលើការបំពេញទម្រង់នៃកំណត់ត្រានៃការអភិវឌ្ឍវិជ្ជាជីវៈបន្តនិងរក្សាទុកដោយខ្លួនឯង។

ខ/ ការណែនាំក្នុងការកត់ត្រាសកម្មភាពសិក្សាសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្តឆ្មបត្រូវប្រើប្រាស់

* <u>ឧបសម្ព័ន្ធទី១</u>៖ កំណត់ត្រាសំរាប់ឆ្មប៖

- កត់ត្រាសកម្មភាពសិក្សាក្នុងការអភិវឌ្ឍវិជ្ជាជីវៈបន្ត ដែលទាក់ទងទៅនឹងការងាររបស់ឆ្មប។
- កត់ត្រារាល់សកម្មភាពសិក្សានីមួយៗ ឬដាក់ជាក្រុមនូវសកម្មភាពសិក្សាដែលប្រហាក់ប្រហែលគ្នាដូចជាវគ្គបណ្តុះបណ្តាល ឬសិក្ខាសាលា ចូលរួមជាអ្នកបង្ហាញ គ្រូសម្របសម្រួល ឬ ជាសិក្ខាកាម។
- កត់ត្រានូវសកម្មភាពសិក្សារបស់ឆ្មប ដើម្បីចងក្រងជាកំណត់ត្រាភស្តុតាងនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត។
- រក្សាទុកឧបសម្ព័ន្ធទី១នេះក្នុងក្រូណូមួយសម្រាប់រយៈពេល៣ឆ្នាំសម្រាប់ការបន្តអាជ្ញាប័ណ្ណឡើងវិញ។

* <u>ឧបសម្ព័ន្ធទី២</u>៖ ចំណាត់ថ្នាក់នៃការកំណត់ពិន្ទុសំរាប់ការិយាល័យក្រុមប្រឹក្សាគណៈឆ្មបរាជធានី/ខេត្ត និង ថ្នាក់កណ្តាល។

* <u>ឧបសម្ព័ន្ធទី៣</u>៖ លិខិតបញ្ជាក់សមត្ថភាពចេញដោយអ្នកអភិបាល។

* ឧបសម្ព័ន្ធទី៤៖ សម្រាប់ស្ថាប័នផ្តល់ការបណ្តុះបណ្តាលឆ្មប ។

ឆ្មបអាចទទួលបានឧបសម្ព័ន្ធទី១ ទី២ ទី៣ និងទី៤ ពីគេហទំព័ររបស់គណៈឆ្មបកម្ពុជា
www.cmidwivesc.org

ឬទំនាក់ទំនងគណៈឆ្មបកម្ពុជាតាមរយៈ Email info.cmccambodia@gmail.comឬ
តាមទូរស័ព្ទលេខ ០១២ ៩៤០ ៥៥២ និង ០១២ ៩៩៧ ៨២៦
ឬទំនាក់ទំនងតាមការិយាល័យក្រុមប្រឹក្សាគណៈឆ្មបរាជធានី-ខេត្តនិងថ្នាក់កណ្តាល ដែលខ្លួនចុះបញ្ជី។

## VIII- ឯកសារយោង

១. ព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈឆ្មបកម្ពុជា
២. អនុក្រឹត្យស្តីពីក្រមសីលធម៌ឆ្មប មាត្រា៥ ( ចំណុចទី ៦)
៣. ច្បាប់ស្តីពីការគ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈវិស័យសុខាភិបាល ជំពូក៣ (មាត្រាទី៦ដល់ទី១០)
៤.ស្តង់ដានៃការផ្តល់អាជ្ញាប័ណ្ណឡើងវិញ និងលក្ខខណ្ឌតម្រូវក្នុងការអភិវឌ្ឍវិជ្ជាជីវៈបន្តសម្រាប់ឆ្មបក្នុងព្រះរាជាណាចក្រកម្ពុជា
៥. គណៈគិលានុបដ្ឋាកសិង្ហបុរី www.healthprofessionals.gov.sg
៦. គណៈគិលានុបដ្ឋាក-ឆ្មបថៃឡង់៖មជ្ឈមណ្ឌលបណ្តុះបណ្តាលបន្ត
www.ccne.or.th/download/sec_license.htlm
៧. គណៈឆ្មបណូវែលសឺឡង់៖ កម្មវិធីផ្តល់វិញ្ញាបនប័ត្រឡើងវិញ
www.midwiferycouncil.health.nz/recertification-elective-education/
៨.គណៈគិលានុបដ្ឋាក-ឆ្មបអូស្រ្តាលី៖ស្តង់ដានៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត
www.nursingmidwiferyboard.gov.au

ឧបសម្ព័ន្ធទី១

## <u>គណៈឆ្មបកម្ពុជា</u>

### ទម្រង់កំណត់ត្រាសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្តរបស់ឆ្មប

I. **អត្តសញ្ញាណឆ្មប៖**

- នាមត្រកូលនិងនាមខ្លួន៖.............................................................................................

- ទីកន្លែងកំពុងបំរើការងារ៖.............................................................................................

.............................................................................................................................

.............................................................................................................................

- តួនាទី៖.............................................................................................................

.............................................................................................................................

II. **ប្រភេទនៃការសិក្សា៖**

- ឈ្មោះវគ្គសិក្សាឬវគ្គបណ្តុះបណ្តាលឬការចុះអភិបាលផ្នែកគ្លីនិក
- ចូលរួមជាៈ សិក្ខាកាម ☐ អ្នកសម្របសម្រួល ☐ អ្នកធ្វើបទបង្ហាញ ☐

.............................................................................................................................

.............................................................................................................................

.............................................................................................................................

III. **រយៈពេលនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត៖**

- ចាប់ពីថ្ងៃទី .......... ខែ ........... ឆ្នាំ........... ដល់ថ្ងៃទី ............ខែ ...............ឆ្នាំ ...............

-ចំនួនម៉ោងដែលបានសិក្សា៖ .............................................................................

- ទីកន្លែងវគ្គសិក្សា៖.............................................................................................

.............................................................................................................................

- ខ្លឹមសារវគ្គសិក្សា៖..............................................................................................................
.........................................................................................................................................
- មូលហេតុនៃការចូលរួម៖ ........................................................................................................
.........................................................................................................................................
.........................................................................................................................................
- ដំណើរការនៃវគ្គសិក្សាយ៉ាងដូចម្ដេច? ......................................................................................
.........................................................................................................................................
.........................................................................................................................................
- តើអ្នកចង់បានអ្វីពីវគ្គសិក្សា៖ ...............................................................................................
.........................................................................................................................................
.........................................................................................................................................

IV. **លទ្ធផលនៃវគ្គសិក្សា៖**

- ទំនាក់ទំនងរវាងលទ្ធផលនៃវគ្គសិក្សាទៅនឹងការងាររបស់អ្នកយ៉ាងដូចម្ដេច?
.........................................................................................................................................
.........................................................................................................................................
- តើវគ្គសិក្សាមានផលប្រយោជន៍អ្វីខ្លះដល់ការអនុវត្តការងារបច្ចុប្បន្នរបស់អ្នក?
.........................................................................................................................................
.........................................................................................................................................
- តើវគ្គសិក្សាធ្វើឲ្យប្រសើរឡើងនូវគុណភាពនៃការផ្ដល់សេវាធ្មបរបស់អ្នកយ៉ាងដូចម្ដេច?
.........................................................................................................................................
.........................................................................................................................................

**បញ្ជាក់៖** អ្នកអាចបន្ថែមចំនួនទំព័រប្រសិនបើចាំបាច់ក្នុងការកត់ត្រាសកម្មភាពរៀនសូត្ររបស់អ្នកនិងរក្សាទុកឧបសម្ព័ន្ធនេះក្នុងក្រូណូរបស់អ្នក។

ហត្ថលេខាសាមីខ្លួន

ឧបសម្ព័ន្ធទី២ **គណៈឆ្មបកម្ពុជា**

## តារាងកំណត់សំរាប់ផ្ដល់ពិន្ទុគិតជាម៉ោងចំពោះសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្តរបស់ឆ្មប

I .សំរាប់សិក្ខាសាលា ឬ វគ្គបណ្ដុះបណ្ដាលក្រៅប្រទេស៖

- ពិន្ទុសំរាប់អ្នកឡើងបង្ហាញ៖
  *គុណនិងបីនៃចំនួនម៉ោងក្នុងថ្ងៃបង្ហាញ (បើអ្នកឡើងបង្ហាញនៅចូលរួមស្ដាប់ពេញមួយថ្ងៃ)
- ពិន្ទុសំរាប់អ្នកចូលរួម៖ ស្មើនិងចំនួនម៉ោងដែលបានចូលរួមគុណនិងពីរ

II .សំរាប់សិក្ខាសាលា ឬ វគ្គបណ្ដុះបណ្ដាលក្នុងប្រទេស៖

- ពិន្ទុសំរាប់អ្នកឡើងបង្ហាញ:
  *គុណនិងពីរនៃចំនួនម៉ោងក្នុងថ្ងៃបង្ហាញ (បើអ្នកឡើងបង្ហាញនៅចូលរួមស្ដាប់ពេញមួយថ្ងៃ)
  *ស្មើនិងចំនួនម៉ោងក្នុងថ្ងៃបង្ហាញ (បើអ្នកឡើងបង្ហាញមិននៅចូលរួមស្ដាប់ពេញមួយថ្ងៃ)
- ពិន្ទុសំរាប់អ្នកសម្របសម្រួល៖បូកបន្ថែមនិង២ម៉ោងក្នុងមួយថ្ងៃ
- ពិន្ទុសំរាប់អ្នកចូលរួម៖ស្មើនិងចំនួនម៉ោងដែលបានចូលរួម

III .សំរាប់ការសិក្សាស្រាវជ្រាវថ្មីៗ៖

- ពិន្ទុសំរាប់អ្នកស្រាវជ្រាវជាបុគ្គល ៖ ស្មើនឹង២០ម៉ោង
- ពិន្ទុសំរាប់អ្នកស្រាវជ្រាវជាក្រុម ៖ ស្មើនឹង២០ម៉ោង(ចែកនឹងចំនួនសមាជិក)

IV.សំរាប់ការសិក្សាតាមប្រព័ន្ធអ៊ីនធឺណែត៖

- ពិន្ទុសំរាប់អ្នកចូលរួម៖ ពិន្ទុសម្រាប់អ្នករៀនតាមប្រព័ន្ធOnline ភ្ជាប់មកជាមួយនិងវិញ្ញាបនបត្រមួយស្មើនិង៨ម៉ោង។

*កំណត់សំគាល់៖

- សំរាប់បទបង្ហាញដែលមានប្រធានបទដែលទទួលបានពិន្ទុបានតែម្ដង
- សំរាប់ការងារស្នូលមិនត្រូវបានរាប់បញ្ចូលទេ (ឧទាហរណ៏គ្រូបង្រៀនឆ្មបនៅសាលា ការរៀបចំគោលនយោបាយសម្រាប់អ្នកធ្វើការនៅការិយាល័យ ។ល។

ឧបសម្ព័ន្ធទី៣

# <u>គណៈឆ្មបកម្ពុជា</u>

## លិខិតបញ្ជាក់សមត្ថភាពចេញដោយអ្នកអភិបាល

នាងខ្ញុំជាឆ្មបដែលបានចុះបញ្ជីនិងទទួលបានអាជ្ញាប័ណ្ណប្រកបវិជ្ជាជីវៈជាមួយគណៈឆ្មបកម្ពុជា ក្នុងប្រភេទឆ្មបទូទៅ ដែលមានលេខ ................................ ក្នុងរាជធានី/ខេត្ត ................................
នាងខ្ញុំបានអភិបាលការអនុវត្តរបស់ឆ្មបឈ្មោះ ................................ សញ្ជាតិ ......... កើតថ្ងៃទី ........ ខែ ............ឆ្នាំ ............... ក្នុងរយៈពេល ............ខែ និងសូមបញ្ជាក់ថា៖
គាត់ពិតជាមានសមត្ថភាពដូចខាងក្រោម ៖ សូមគូសសញ្ញាក្នុងប្រអប់ និងចុះហត្ថលេខានៅក្បែរនោះ

១. សមត្ថភាពក្នុងសង្គម អេពីដេមីសាស្រ្ត បរិបទវប្បធម៌នៃការថែទាំមាតា និងទារកទើបកើត ☐
២. សមត្ថភាពក្នុងការថែទាំមុនពេលមានផ្ទៃពោះ និងសេវាពន្យារកំណើត/ផែនការគ្រួសារ ☐
៣. សមត្ថភាពក្នុងការថែទាំក្នុងអំឡុងពេលមានផ្ទៃពោះ ☐
៤. សមត្ថភាពក្នុងការថែទាំក្នុងអំឡុងពេលឈឺពោះសម្រាល និងពេលសម្រាល ☐
៥. សមត្ថភាពក្នុងការផ្តល់ការថែទាំដល់ស្ត្រីក្រោយពេលសម្រាល ☐
៦. សមត្ថភាពនៃការថែទាំទារកទើបកើតក្រោយសម្រាល ☐
៧. សមត្ថភាពក្នុងការសម្របសម្រួលលើការថែទាំការរំលូត ☐

សូមគាំទ្រការបន្តអាជ្ញាប័ណ្ណរបស់គាត់ជាមួយគណៈឆ្មបកម្ពុជា។

**អ្នកអភិបាល**

ធ្វើនៅ ............... ថ្ងៃទី................ខែ ......... ឆ្នាំ............

ហត្ថលេខា និងឈ្មោះ

**បានឃើញ និងឯកភាព**

ធ្វើនៅ ............... ថ្ងៃទី................ខែ ........ .ឆ្នាំ ............

ប្រធានមន្ទីរពេទ្យ/ មណ្ឌលសុខភាព/គ្លីនិក

ហត្ថលេខា និងឈ្មោះ

ឧបសម្ព័ន្ធទី៨

**គណៈឆ្មបកម្ពុជា**

សំរាប់ស្ថាប័នបណ្តុះបណ្តាលវិជ្ជាជីវៈបន្តរបស់ឆ្មប

ស្ថាប័នរៀបចំវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈបន្តរបស់ឆ្មបមាន៖

- សេវាសាធារណៈ , ឯកជន , អង្គការក្រៅរដ្ឋាភិបាល , មន្ទីរពេទ្យ , សមាគមវិជ្ជាជីវៈ ។ល។
- គ្រប់វគ្គបណ្តុះបណ្តាល / សិក្ខាសាលា / សន្និសីទ ………… ។ល។

សូមជូនដំណឹងមកការិយាល័យគណៈឆ្មបឲ្យបានមុនពេល១០ ថ្ងៃ (ថ្ងៃធ្វើការ) និងភ្ជាប់មកជាមួយនូវ ៖

- លិខិតជូនដំណឹង (តាមបែបបទរដ្ឋបាល)
- កម្មវិធី (Agenda)
- ប្រវត្តិការងារសង្ខេបរបស់អ្នកធ្វើបទបង្ហាញ / គ្រូឧទ្ទេសនាម (CV)
- បទបង្ហាញ / គំរោងមេរៀន

*** វគ្គបណ្តុះបណ្តាលត្រូវតែផ្អែកទៅតាមក្របខណ្ឌសមត្ថភាពស្នូលសម្រាប់វិជ្ជាជីវៈឆ្មប

**បញ្ជាក់៖** គណៈកម្មការគណៈឆ្មបនឹងធ្វើការត្រួតពិនិត្យ និងវាយតម្លៃពិន្ទុផ្តល់ជូនដោយផ្អែកទៅតាមគោលការណ៍ណែនាំរបស់គណៈឆ្មបកម្ពុជា សំរាប់តែវគ្គបណ្តុះបណ្តាល / សិក្ខាសាលា / សន្និសីទ……..ណា ដែលគណៈឆ្មបទទួលបានការជូនដំណឹងតែប៉ុណ្ណោះ ។